នាយកដ្ឋានអប់រំពិសេស

# សេចក្តីជូនដំណឹងអំពីការស្វែងរកកុមារប្រចាំឆ្នាំ

ដោយអនុលោមតាមតម្រូវការនៃច្បាប់ស្តីពីការអប់រំសំរាប់ជនពិការ (IDEA) សង្កាត់សាលារៀនអូកឡិនដ៍ ត្រូវតែកំណត់ ស្វែងរក វាយតម្លៃលើកុមារដែលរស់នៅក្នុងទីក្រុងអូកឡិនដ៍តាំងពីកំណើតរហូតដល់អាយុ 21 ឆ្នាំ ដែលជាប់ការសង្ស័យថាមានភាពពិការផ្លូវចិត្ត ផ្លូវកាយ ផ្នែកទំនាក់ទំនងគ្នា ឬអារម្មណ៍។ កាតព្វកិច្ចនេះត្រូវបានគេហៅថា ការស្វែងរកកុមារ ។ ព័ត៌មានដែលផ្តល់មកដោយក្រុមគ្រួសារ និងទីភ្នាក់ងារទាំងឡាយ ដែលគាំទ្រកុមារនៅក្នុងសហគមន៍មូលដ្ឋាន នឹងត្រូវបានប្រើប្រាស់ក្នុងការគាំទ្រដល់គោលដៅរបស់សង្កាត់ ដើម្បីធានាឱ្យកម្មវិធីអប់រំរបស់រដ្ឋត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ និងសមរម្យសម្រាប់កុមារទាំងអស់ដែលរស់នៅក្នុងព្រំប្រទល់របស់សង្កាត់។

ព័ត៌មានដែលត្រូវបានផ្តល់ជូនមកទាក់ទងនឹងកុមារ នឹងត្រូវប្រើប្រាស់ស្របតាមច្បាប់ស្តីពីសិទ្ធិអប់រំ និងឯកជនភាពរបស់ក្រុមគ្រួសារ (FERPA)។ មាតាបិតា/អ្នកមានសិទ្ធិលើការអប់រំ ត្រូវបានធានាឱ្យមានសិទ្ធិចូលពិនិត្យមើល និងធានាឱ្យមានភាពត្រឹមត្រូវនៃកំណត់ត្រាអំពីកម្មវិធីអប់រំណាមួយដែលសង្កាត់រក្សាទុកទាក់ទងទៅនឹងកូនរបស់លោកអ្នក។

ប្រសិនបើលោកអ្នកសង្ស័យថាកូនរបស់លោកអ្នក ឬកូនណាម្នាក់របស់លោកអ្នកដឹងថាអាចមានពិការភាព ដែលត្រូវការសេវាកម្មអប់រំពិសេសនោះ សូមទាក់ទងអ្នកសម្របសម្រួលផ្នែកស្វែងរកកុមាររបស់សង្កាត់នៅ៖

| |
|---|
| **Early Childhood**<br>(ផ្នែកអប់រំកុមារតូច)<br>Silvia Nuno<br>(510) 729-7771<br>silvia.nuno@ousd.org |
| **All Other Students**<br>(ចំពោះសិស្សទាំងអស់ផ្សេងទៀត)<br>Peggy Forbes<br>(510) 879-8090<br>peggy.forbes@ousd.org |

**ousd.org/specialeducation**

OAKLAND UNIFIED SCHOOL DISTRICT
Community Schools, Thriving Students

# នាយកដ្ឋានអប់រំពិសេស

អ្នកសម្របសម្រួលផ្នែកស្វែងរកកុមារ ធ្វើការធានាយ៉ាងណាឱ្យនីតិវិធីសមស្រប ចាប់ពីការវាយតម្លៃរហូតដល់ការសម្រេចរបស់ខ្លួន ត្រូវបានអនុវត្តតាមរបៀបដែលប្រកាន់ខ្ជាប់តាមច្បាប់រដ្ឋ និងសហព័ន្ធ។ ពេលទទួលបានព័ត៌មានអំពីកុមារដែលអាចត្រូវការកម្មវិធីអប់រំពិសេសនោះ អ្នកសម្របសម្រួលនឹងពិនិត្យឡើងវិញលើព័ត៌មាន និងធ្វើការកំណត់ថា តើការវាយតម្លៃលើកម្មវិធីអប់រំពិសេសមួយនេះ ជាតម្រូវការចាំបាច ដែរយ៉ាងណា។ ព័ត៌មានច្រើនថែមទៀត ដែលមានលក្ខណៈជាក់លាក់ទាក់ទងទៅនឹងជំហានពាក់ព័ន្ធនឹងដំណើរនៃកម្មវិធីអប់រំពិសេសនោះ នឹងត្រូវបានដាក់ពន្យល់ជូននៅក្នុងពេលហ្នឹង ហើយមាតាបិតា/អ្នកមានសិទ្ធិអប់រំកុមារ នឹងទទួលបាននូវឯកសារចម្លង និងសេចក្តីពន្យល់ជូន មួយច្បាប់ អំពីនីតិវិធីការពារដែលជាឯកសារមួយច្បាប់ពន្យល់អំពីសិទ្ធិ និងការការពារដែលជាប់ពាក់ពាន់ការវាយតម្លៃ និងសេវាកម្មអប់រំ ពិសេស។

**ousd.org/specialeducation**